

# សភាពនៃទំនាក់ទំនង ការលូតលាស់៖ ការអភិវឌ្ឍន៍ទាំង អតិថិជន និងអ្នកព្យាបាល

សង្គ្រាមរ៉ាំរ៉ៃរបស់កម្ពុជា បញ្ហាជាច្រើននៅសង្គម និងជាប្រទេសកំពុងអភិវឌ្ឍន៍ ទាំងនេះធ្វើអោយប្រជាជនភាគច្រើនរស់នៅក្នុងសភាពភ័យខ្លាច។ ប្រជាជនជាច្រើនទទួលរងនូវការបាក់ស្បាត មិនទុកចិត្តគ្នា និងបាត់បង់ទំនាក់ទំនងវិជ្ជមានក្នុងការរស់នៅប្រចាំថ្ងៃ។ ប្រជាជនកម្ពុជាជាច្រើនគ្មានការជឿទុកចិត្តគ្នាគ្រប់គ្រាន់ទេ ជាពិសេសការចែករំលែកបញ្ហាផ្សេងៗ ដោយសារគ្មានអារម្មណ៍សុវត្ថិភាព ជាមួយមនុស្សជុំវិញគាត់។

ពេលដែលខ្ញុំចាប់ផ្តើមរៀនវគ្គប្រឹក្សាផ្លូវចិត្តបែបវិជ្ជាជីវៈ ខ្ញុំមានអារម្មណ៍សប្បាយចិត្តព្រោះវាជាក្តីស្រម៉ៃរបស់ខ្ញុំក្លាយជាអ្នកប្រឹក្សាមួយរូប។ ទោះជាយ៉ាងណាក៏ខ្ញុំមានក្តីបារម្ភជាមួយនឹងវគ្គនេះផងដែរពីព្រោះការរៀនត្រូវការលះបង់ពេលវេលា និងមានឆន្ទៈខ្ពស់ហើយការសិក្សារទៀតសោតត្រូវផ្តោតលើសម្ថភាពផ្ទាល់ខ្លួន។
ការដាក់ពិន្ទុផ្អែកទៅលើការចូលរួម ហើយរបៀបប្រលងក៏មានលក្ខណះតឹងរឹងទៀត។ ខ្ញុំត្រូវធ្វើការឆ្លុះបញ្ចាំងដែលពិតជាត្រូវការចំនាយទាំងពេលវេលា ព្រមទាំងកម្លាំងកាយ និងចិត្តច្រើន។ វាពិតជាមានការខុសប្លែកគ្នាច្រើនបើធៀបទៅការសិក្សាដែលខ្ញុំធ្លាប់បានចូលរួមពីមុនៗមក។
ខ្ញុំធ្លាប់ឆ្លងកាត់ការសិក្សាហើយទទួលបានសញ្ញាបត្រច្រើនប៉ុន្តែខ្ញុំដឹងថាវាដូចជាមិនសមនឹងទទួលបានសោះ។ វាមិនតម្រូវអោយមានការចូលរួមក្រុមច្រើន។

ភាពជោគជ័យនៅក្នុងវគ្គប្រឹក្សាយោបល់ដែលមានវិជ្ជាជីវះ វាជារឿងដែលខ្ញុំមានមោទនៈភាព។ ចំនេះដឹងដែលខ្ញុំទទួលបានគឺបានដោយសមត្ថិភាពផ្ទាល់របស់ខ្ញុំ។ ខ្ញុំធ្វើការឆ្លុះបញ្ចាំងលើការរីកចំរើនរបស់ខ្ញុំ។ ខ្ញុំទទួលបានចំនេះដឹងថ្មីៗ ហើយថែមទាំងទទួលបាននៅការជាសះដោយសារមានទំនាក់ទំនងនៃការជឿទុកចិត្តជាមួយមិត្តរួមថ្នាក់។ យើងគោរពគ្នាទៅវិញទៅមកហើយទទួលយកភាពផ្សេងគ្នារបស់បុគ្គលនិមួយៗ។ យើងបានអនុវត្តទំនាញប្រឹក្សាយោបល់ជាមួយគ្នាដោយគោរពតាមគោលការណ៍ក្រមសីលធម៍ដែលបានកំណត់ដោយសមាគមន៍ចក្រភពអង់គ្លេសសម្រាប់អ្នកប្រឹក្សាយោបល់ និងអ្នកព្យាបាលផ្លូវចិត្ត។

ព្យាយាមដើរតាមស្តង់ដារនេះមានន័យថាខ្ញុំមានបទពិសោធន៍នៃទំនាក់ទំនងជាមួយមិត្តរួមថ្នាក់នៃការមិនវិនិច្ឆ័យ ដែលវាធ្វើអោយខ្ញុំមានអារម្មណ៍សុវត្ថិភាពក្នុងការចែករំលែកនូវបញ្ហាជីវិតរបស់ខ្ញុំដែលបានកប់ជ្រៅនៅក្នុងខ្ញុំ។ ភាពជាសះបានចាប់ផ្តើមចេញពីខ្ញុំ។ ហើយអ្វីដែលពិសេសជាងនេះ ខ្ញុំទទួលបានគឺពីលោកគ្រូអ្នកគ្រូដែលគាត់មានបទពិសោធន៍និងវិធីសាស្រ្តល្អៗក្នុងការបង្ហាត់បង្រៀន និងមានការលើកទឹកចិត្ត ដល់សិស្សគ្រប់ៗគ្នារាល់ពេលយើងឆ្លើយសំនួរមានន័យថាយើងមានការផ្សារភ្ជាប់រវាងគ្រូនិងសិស្សពេលកំពុងរៀន។ ហើយព្រមទាំងបានទទួលការព្យាបាលពិសេសពីអ្នកឯកទេសដែលគាត់មានវិជ្ជាជីវៈច្បាស់លាស់ និងមានបទពិសោធន៍ជាអ្នកព្យាបាលដែលប្រកបដោយក្រមសីលធម៌ផងដែរ។

សរុបមក ការសិក្សារបស់ខ្ញុំបានលើកកំពស់ និងពង្រឹងដល់ការងាររបស់ខ្ញុំ។ នៅពេលខ្ញុំឆ្លុះបញ្ចាំងទៅអតិថិជន ពួកគេស្រដៀងនឹងខ្ញុំពេលខ្ញុំចាប់ផ្តើមចូលរៀនវគ្គប្រឹក្សាសុខភាពផ្លូវចិត្តដែរ។ ពួកគេមានការលំបាកក្នុងការចែកចាយនូវអារម្មណ៍ និងបញ្ហារបស់ពួកគេ។ ពួកគេមានជីវិតដែលប៉ះទង្គិចដោយការប៉ះទង្គិចផ្លូវចិត្ត ហើយគ្មានអារម្មណ៍សុវត្ថិភាពក្នុងការចែកចាយពីបញ្ហារបស់ពួកគេទៅមនុស្សដែលគាត់ស្គាល់ទោះទេ។ ក្រោយពីបានសិក្សាស្វែងយល់ និងទទួលបានបទពិសោធន៍នៅក្នុងថ្នាក់ដែលខ្ញុំខ្លួនឯងជាអ្នកព្យាបាលផង និងជាអតិថិជនផង ព្រមទាំងការធ្វើការផ្ទាល់ជាមួយអតិថិជននៅកន្លែងការងារ វាបានធ្វើអោយខ្ញុំអាចឆ្លុះបញ្ចាំងថា ការដែលអតិថិជន និងអ្នកព្យាបាលបានកសាងទំនាក់ទំនងបានល្អវាដូចជាស្ពានមួយដែលមានគ្រឹះរឹងមាំ ដែលអាចអោយភាគីទាំងពីបន្តដំណើរដើម្បីឈានដល់ភាពរីកចំរើន និងការជាសះស្បើយ។

## ប្រវត្តិរូប :



Nimol is in her second year studying professional health counselling at the University of Puthisastra.